THE SPACE IN BETWEEN

FEATURING ORIGINAL ARTWORKS BY:
CHAN DANY | KET MONNYREAK | KHVAY SAMNANG | HEAN RANGSEY | LIM SOK-CHANLINA | NATALY LEE | PEN ROBIT | PRAK DALIN | ROEUN SOKHOM | THANG SOTHEA | VUTH LYNO

ART EXHIBITION

“WE BORROW FROM NATURE THE SPACE UPON WHICH WE BUILD.”

TADAO ANDO

ការតាំងពិព័រណ៌នេះនាំមកជូនលោកអ្នកនូវសិល្បករ 11 រូបដែលក្នុងនោះរួមមាន កេត មុន្នីរ័ក្ស ខ្វៃ សំណាង ហ៊ាន រង្សី លីម សុខចាន់លីណា លី ណាតាលី ប៉ែន រ៉ូប៊ីត ប្រាក់ ដាលីន រឿន សុខុម ថាំង សុធា វុធ លីណូ និងចាន់ ដានី។ ស្នាដៃរបស់សិល្បករនីមួយៗបង្ហាញអំពីគោលគំនិត ការរស់នៅ ការយល់ឃើញ នៅក្នុងសង្គម។ ការតាំងពិព័រណ៌នេះមានគោលបំណងចង់ស្វែងយល់បន្ថែមអំពីសំណួរចាំបាច់មួយចំនួននៅក្នុងវិស័យសិល្បៈ ក៏ដូចជាដំណើរការក្នុងការបង្កើតស្នាដៃទាំងនេះឡើងផងដែរ។ យើងនឹងឆ្លើយសំណួរដូចជា អ្វីទៅគឺជាសិល្បៈ? តើសិល្បករផលិតស្នាដៃរបស់ខ្លួនដោយរបៀបណា? ហើយក្នុងពេលតែមួយនោះយើងក៏នឹងសិក្សាបន្ថែមអំពីការរស់នៅដ៏ជិតស្និទ្ធជាមួយនឹងស្ថាបត្យកម្ម ធម្មជាតិ និងសិល្បៈផងដែរ។

យើងខ្ញុំសង្ឃឹមថាការដាក់បង្ហាញសិល្បៈនេះនឹងផ្តល់ឱកាសឲ្យសិល្បករ និងអ្នកដែលស្រលាញ់ចូលចិត្តសិល្បៈ បានជួបគ្នាដើម្បីសិក្សាពីស្នាដៃផ្សេងៗ និងយល់ដឹងពីការប្រមូលសមុច្ច័យសិល្បៈផងដែរ។

This exhibition brings together works from eleven Cambodian artists—Khvay Samnang, Vuth Lyno, Lim Sokchanlina, Thang Sothea, Pen Robit, Ket Monnyreak, Prak Dalin, Hean Rangsey, Roeun Sokhom, Nataly Lee and Chan Dany. Each artist presents individual ideas, ways of living, seeing, and thinking. The exhibition explores some of the fundamental questions of art and its making (for example: What is art? How do artists create their work?) while exploring the idea of living with architecture, nature and art.

We hope the exhibition will be a place for art lovers and collectors of all types to come together and learn about the artists, their work and the world of art collecting in general.

ខ្វៃ សំណាង / KHAY SAMNANG

ខ្វៃ សំណាង មានដើមកំណើតនៅខេត្តស្វាយរៀង ភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ ប្រជាជនដែលរស់នៅតំបន់នោះ នៅតែរស់នៅយ៉ាងជិតស្និទ្ធិជាមួយនឹងធម្មជាតិ នៅឡើយ ហើយវាបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើការងារសិល្បៈរបស់សំណាង។ ការងាររបស់សំណាងផ្តោតទៅលើផលប៉ះពាល់នៃនគរូបនីយកម្មទៅលើមនុស្សជាតិ និងបរិស្ថានធម្មជាតិ។ ការបង្កើតសិល្បៈរបស់លោក បង្កើតជាទស្សនៈថ្មីមួយទៅលើ ប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍ថ្មីៗ និងទំនៀមទម្លាប់ខ្មែរ ដោយប្រើប្រាស់ភាពផ្ទុកកំប្លែង និងក្បាច់រាំដែលមានអត្ថន័យបង្កប់។ ស្នាដៃនីមួយៗរបស់លោកកើតចេញពីការសិក្សា ស្រាវជ្រាវយ៉ាងស៊ីជម្រៅទៅលើការរស់នៅ ជំនឿ និងលក្ខខណ្ឌរស់នៅរបស់មនុស្ស នៅតាមតំបន់ផ្សេងៗនៅប្រទេសកម្ពុជា។ ដូច្នេះដើម្បីបង្កើតសិល្បៈឡើង សំណាង បានធ្វើដំណើរទៅជាច្រើនកន្លែង ដើម្បីអង្កេតមើលការរស់នៅយ៉ាងជិតស្និទ្ធិរបស់ មនុស្សជាមួយធម្មជាតិ។

Khvay Samnang was born in Svay Rieng province in Southeastern Cambodia where people still live closely with nature. His background inspires his works, focusing on the humanitarian and ecological impacts of colonialism and urbanisation. Samnang's practice offers new views on history, current events and traditional cultural rituals using humorous, and symbolic gestures. Each body of work is based on thorough research and investigation of local specificities, structures, and conditions. To do so, Samnang travels frequently to observe the way people live.

Khvay Samnang
POPIL, 2018
Digital C-Print
80 x 120 cm
Edition of 3 + 2AP

Khvay Samnang
POPIL, 2018
Digital C-Print
80 x 120 cm
Edition of 3 + 2AP

ពិធីបង្វិលពពិល គឺជាពិធីមួយដែលប្រជាជនខ្មែរប្រារព្ធឡើងនៅក្នុងពិធីកាត់សក់បង្កក់កូន ឆ្លងវ័យ មង្គលការ បុណ្យសព និងពិធីផ្សេងៗទៀត។ គេធ្វើពិធីនេះ ដើម្បីអន្ជើញហៅព្រលឹងទាំង 19 អោយមកចូលប្រសព្វក្នុងខ្លួនវិញ ព្រោះបើខ្វះព្រលឹងណាមួយ បុគ្គលនោះច្បាស់ទៅជាឈឺ ឬមិនស្រួលដោយប្រការណាមួយមិនខាន។ នៅក្នុងពិធីមង្គលការ គេបង្វិលពពិលដើម្បីហៅព្រលឹងទាំងអស់របស់គូស្វាមីភរិយាថ្មីមកវិញ និងដើម្បីបង្កភោគផលនិងកំណកំណើតកូនចៅដល់គូនោះផង។ ចំណែកឯស្នាដៃពពិល របស់សំណាងវិញ គឺជាការសម្តែងជាមួយក្បាច់របាំថ្មីមួយដោយនាដការពីររូបគឺ មុត ផារ៉ាន់ និង សុត សុវណ្ណឌី ស្តែងចេញជារឿងមេត្រីភាពរវាងសត្វនាគមួយគូ។ នៅក្នុងខ្សែវីដេអូ នាគមួយគូនេះរាំក្បាច់ពត់ពេន ហោះហើររេរា បង្វិលនៀល និងធ្វើដំណើរយាត្រាចរពីភូមិភាគខាងជើងនៃប្រទេសកម្ពុជា មកដល់ទីក្រុងភ្នំពេញ ហើយឆ្ពោះទៅភូមិភាគខាងត្បូងប្រទេស ឆ្លងកាត់ព្រៃភ្នំ សមុទ្របឹងបួរ និងទីក្រុងដែលកំពុងអភិវឌ្ឍនិងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ កាយវិការបង្វិល និងក្បាច់រាំរបស់ពួកគេ មិនត្រឹមតែបង្ហាញពីភាពស្និទ្ធស្នាល ស្នេហាមេត្រីភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងភាពតានតឹងនិងជម្លោះ ក៏ដូចជាដំណើររឿងផ្សេងៗតាមបែបបួងសួងក្នុងពិធីសាសនាផងដែរ។ ការសម្តែងរបស់នាគទាំងពីរ នៅលើទីតាំងភូមិសាស្ត្រសំខាន់ៗទាំងនេះ ហាក់ចង្អុលលើសពីទំនាក់ទំនងស្នេហា ដល់ទំនាក់ទំនងនយោបាយដ៏ស្មុគស្មាញរវាងតួអង្គទាំងពីរនៅលើទឹកដីមួយនេះ។

Popil is a ritual Cambodian hold at ceremonies such as baby showers, coming of age, weddings, funerals, and other ceremonies. The passing of Popil in a circle refers to the cycle of life. People perform this ritual to call all the 19 souls of a person to return to the body, because if any of the souls is missing, the person would become sick or unstable. At a wedding, people perform Popil to call back the couple's souls and ask for prosperity and reproduction. Here, Samnang's Popil is instead a performance choreographed and danced by two Cambodian classical dancers, Mot Pharan and Sot Sovanndy, telling a story of the courtship between two dragons. In the video, the couple dances, flies, twists, and twirls, traversing from the northern part of Cambodia to Phnom Penh capital and then the southern part of the country, passing through the sea and mountains, forests, and the cities that are rapidly growing. Their movements and gestures express not only intimacy and love, but also tension and fight while telling narratives of ritual. Their presence across critical geographies suggests beyond a romantic relationship to one that is also political.

Khvay Samnang
POPIL, 2018
Digital C-Print
80 x 120 cm
Edition of 3 + 2AP

Khvay Samnang
POPIL, 2018
Digital C-Print
80 x 120 cm
Edition of 3 + 2AP

វុធ លីណូ / VUTH LYNO

វុធ លីណូ គឺជាសិល្បករ អ្នកថែរក្សារៀបចំពិព័រណ៍សិល្បៈ និងអ្នកអប់រំម្នាក់ ដែលចាប់អារម្មណ៍លើលំហ ប្រវត្តិវប្បធម៌ និងការបង្កើតចំណេះដឹងថ្មីៗ។ ស្នាដៃរបស់លោកភាគច្រើនផ្តោតទៅលើ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលគេមើលរំលង ជំនឿតាមសហគមន៍ ការរៀបចំទីធ្លាសាធារណៈ និងការបង្កើតនូវទំនាក់ទំនងសង្គមជាដើម។ ការតម្លើងសិល្បៈរបស់លោកបង្ហាញយើងអំពីរឿងរ៉ាវរបស់មនុស្ស តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដូចជារូបថត វីដេអូ ចម្លាក់ ពន្លឺ និងសម្លេងជាដើម។

Vuth Lyno is an artist, curator, and educator, interested in space, cultural history, and knowledge production. His artworks often engage with micro and overlooked history, the notion of community, place-making, and the production of social relations. His installations showcase human stories, depicted through a range of media, including photography, video, sculpture, light, and sound.

លីណូ ដាក់បង្ហាញជូននូវស្នាដៃរូបភាពធ្វើពីសន្លឹកលោហៈពណ៌មាសចំនួន 5 ផ្ទាំង ដែលមានរាងជារូបជំនាងផ្ទះ។ ប្រណិប័តន៍ជំនាងផ្ទះនៅកម្ពុជា បានទទួលឥទ្ធិពលពីវប្បធម៌ចិន ដោយគេមានជំនឿថាមានព្រលឹងនៅប្រចាំថែរក្សាផ្ទះនីមួយៗ។ គេដាក់ជំនាងផ្ទះ ដែលសង់ឡើងជារូបកូនផ្ទះ នៅផ្ទាល់ដីបែរមុខមកក្រៅចំច្រកចូលលំនៅដ្ឋាន ឬអគារអាជីវកម្មនានា។ ស្នាដៃលោហៈពណ៌មាសទាំង 5 ផ្ទាំងនេះ ត្រូវបានដាក់តម្រៀបគ្នាជាជួរលើជញ្ជាំង បង្ហាញជារូបជំនាងផ្ទះក្នុងរចនាបទផ្សេងៗគ្នា។ រូបទាំងនេះភ្លឺរលោងចាំងដូចកញ្ចក់ និងឆ្លុះពីរូបភាពនៅទល់មុខវា ដូច្នេះអ្វីដែលយើងឃើញនៅក្នុងកញ្ចក់នោះប្រែប្រួលជានិច្ច នៅពេលយើងដើរកាត់វា។ មិនថាតាមរយៈពន្លឺ ឬរូបភាពឆ្លុះនោះទេ ស្នាដៃនិងការបង្ហាញរបស់លីណូ បង្កើតឲ្យមានបទពិសោធន៍ និងរូបភាពថ្មីមួយ ហាក់ដូចជាបង្កើតបាននូវលំហថ្មីនៃពិភពមួយផ្សេងទៀត សម្រាប់ជំនួបមិននឹកស្មានដល់រវាងទស្សនិកជន និងជំនាងផ្ទះ។

Lyno introduces five images of a kind of shrine called Chumneang Pteah (house spirit). Cambodian house spirit is influenced by a Chinese practice belief that a spirit takes care of each house. People place the shrines, which are usually made of miniature houses, on the ground facing out to the entrance of a residence or home business. The five wall pieces are made of alluring golden stainless steel, outlining Chumneang Pteah in various designs. They are shiny and reflect like mirrors, producing ever-changing reflected images as the audience walks past them. Whether it is a light or a reflection, Lyno's work creates a new experience and vision as if constructing an otherworldly space for the interface between the audience and the house spirit.

Vuth Lyno
Mirror Shrine 1, 2022
Stainless steel with aluminum backing
57 x 59 cm
Edition of 4 + 1AP

Vuth Lyno
Mirror Shrine 2, 2022
Stainless steel with aluminum backing
50 x 59 cm
Edition of 4 + 1AP

Vuth Lyno
Mirror Shrine 3, 2022
Stainless steel with aluminum backing
54.6 x 68 cm
Edition of 4 + 1AP

Vuth Lyno
Mirror Shrine 4, 2022
Stainless steel with aluminum backing
78.8 x 65.6 cm
Edition of 4 + 1AP

Vuth Lyno
Mirror Shrine 5, 2022
Stainless steel with aluminum backing
78.8 x 65.6 cm
Edition of 4 + 1AP

លីម សុខចាន់លីណា / LIM SOKCHANLINA

Lim Sokchanlina
Areng Valley, Koh Kong Province, 2018
Paper: Ilford Smooth Cotton Rag 310g
104 x 156 cm
Edition 2/5 + 2AP

លីណា បង្កើតស្នាដៃក្នុងទម្រង់ជា ភាពយន្តឯកសារ រូបថត វីដេអូ និងការតម្លើងសិល្បៈ។ សិល្បៈដែលលោកបង្កើតមក ចោទសំណួរទៅលើការផ្លាស់ប្តូរនៅក្នុងសង្គម នយោបាយ ភូមិសាស្ត្រ និងវប្បធម៌នៅក្នុងប្រទេសកម្ពុជា។ លោកក៏មានការសម្តែងដែលបង្ហាញអំពីការផ្លាស់ប្តូរនៃសេដ្ឋកិច្ច និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅប្រទេសកម្ពុជា ដែលទទួលឥទ្ធិពលពីអំណាច និងការផ្លាស់ប្តូរនៃសេដ្ឋកិច្ចពិភពលោកផងដែរ។ លីណា គឺជាសមាជិកជើងចាស់នៅក្រុមសិល្បករ Stiev Selapak ម្នាក់ និងជាសហស្ថាបនិកនៃគម្រោងសិល្បៈ ស-ស ផងដែរ។ ជារួមគម្រោងនេះជម្រុញការអភិវឌ្ឍនៃវិស័យសិល្បៈសហសម័យនៅកម្ពុជា។

Lina works with documentary, conceptual and experimental photography, video and installation to examine social, political, geopolitical and cultural changes in Cambodia. His performing arts also examine economic changes in Cambodia in relation to the global notion of what power and economics play roles in our everyday life and contemporary world. He is a longtime member of the artist collective Stiev Selapak, and co-founded Sa Sa Art Projects. Together, they facilitate the development of the Cambodian contemporary art scene.

គម្រោងសិល្បៈ ***Wrapped Future II ប្រើប្រាស់របងស័ង្កសី*** ដើម្បីដាក់តាំងនៅតាមទីតាំងធម្មជាតិផ្សេងៗដូចជាស្ទឹង បឹងបួរ ជន្លងភ្នំ ព្រៃស្រោងជាដើម ដោយដាក់តាំងវានៅចំកណ្តាលរូបថតឲ្យបាំងបិតនូវទេសភាពជុំវិញដ៏ស្រស់ស្អាតរបស់ប្រទេសកម្ពុជា។ ទេសភាពដែលមិនចុះសម្រុងគ្នានេះឆ្លុះបញ្ចាំង តាមរយៈធាតុដែលបង្កើតដោយមនុស្ស និងធម្មជាតិដែលនៅពីក្រោយវា។

រូបភាពទាំងនេះ ត្រូវបានថតនៅទីតាំងដែលរងគ្រោះពីការអភិវឌ្ឍ ដែលមិនមានការគ្រប់គ្រងត្រឹមត្រូវក្នុងពេលថ្មីៗនេះ។ ដោយប្រើប្រាស់របងនេះដើម្បីតាងឲ្យការផ្លាស់ប្តូរ លើណាចង់បង្ហាញប្រាប់យើងអំពីភាពមិនប្រាកដប្រជាអំពីអនាគតនៃសហគមន៍ វប្បធម៌ និងធនធានធម្មជាតិខ្មែរដែលនឹងអាចបាត់បង់បន្តិចម្តងៗ។ ទិដ្ឋភាពបែបនេះយើងអាចឃើញសឹងតែគ្រប់ទីកន្លែងនៅជុំវិញប្រទេសកម្ពុជា។ មិនយូរប៉ុន្មានក្រោយពីគេដករបងនេះចេញ ទិដ្ឋភាពខាងក្រោយ នឹងផ្លាស់ទៅជាអគារថ្មីស្រឡាង បន្តបិតបាំងធម្មជាតិដែលធ្លាប់នៅទីនោះពីមុន។ របងស័ង្កសីទាំងនេះគឺជាគ្រោងបណ្តោះអាសន្ន ដែលបង្ហាញយើងបន្តិចម្តងៗនូវអគារ ឬគ្រោងសំណង់ដែលលាក់ខ្លួនពីខាងក្រោយ។

An ongoing project, ***Wrapped Future II brings fences***, used on construction sites to enclose the surrounding areas, to different locations, lakes, valleys and forests, and places them at the centre of photo-works to obscure the beautiful Cambodian landscape. The inharmonious landscape is gradually captivated by the exquisite balance between inorganic material and mystical background.

The photos were taken in places that have become targets of large-scale exploitation under massive globalization of capital and other political interests in recent years. Using the fences as a symbol of change, Lina is warning us about an uncertain future where local realities with their communities, culture and nature will slowly fade away. Landscapes featuring fences are a typical sight. Although quite dull in themselves, once fences are removed, soon enough that very same spot will upgrade its status within the urban landscape as a brand-new building. Some occupying the whole screen, others left open on both sides. These fences, too, are mere temporary structures, however, we start to see them as borders dividing here and there once, we understand what they are hiding.

Lim Sokchanlina
Tonle Sap Lake,
Siem Reap Province, 2022
Paper: Ilford Smooth Cotton Rag 310g
70 x 105 cm
Edition 1/5 + 2AP

Lim Sokchanlina
Mekong River,
Stung Treng Province, 2018
Paper: Ilford Smooth Cotton Rag 310g
70 x 105 cm
Edition 2/5 + 2AP

ថាំង សុធា / THANG SOTHEA

ថាំង សុធា ធ្លាប់ធ្វើការជាស្ថាបត្យករមុនពេលលោកចូលប្រឡូកក្នុងវិស័យសិល្បៈ។ ចម្លាក់ និងការដាក់តាំងបង្ហាញរបស់លោកប្រើប្រាស់វត្ថុ និងការដាក់តម្លើងសិល្បៈដែលបង្ហាញពីសេរីភាពរបស់សិល្បករក្នុងការស្វែងយល់បន្ថែមអំពីស្ថាបត្យកម្ម និងសិល្បៈ។ លោកអនុញ្ញាតឲ្យយើងឃើញនូវរូបរាងថ្មីនៃវត្ថុបុរាណ និងសណ្ឋានធម្មជាតិ ដោយផ្សាភ្ជាប់វាជាមួយនឹងប្រវត្តិសាស្ត្រ និងទំនាក់ទំនងរវាងលំហ និងវត្ថុនៅក្នុងលំហនោះ។ ស្នាដៃរបស់សុធា ត្រូវបានគេទទួលស្គាល់ និងយកទៅដាក់តាំងបង្ហាញនៅជាច្រើនកន្លែងពាសពេញប្រទេសកម្ពុជា។

Thang Sothea began his career as an architect before venturing into art. Sothea's sculptures and installations are made using materials and processes intentionally associated with a sense of freedom to explore architecture and art. His work allows us to reimagine the traditional materials and natural forms, and to connect with history and the relationship between volume and space. His installation works are widely featured around Cambodia.

ការងារនេះ ជាការងារបន្តពីការធ្វើចម្លាក់ពីមុនរបស់សុធា ដែលមានចំណងជើង មនុស្ស និងទេវតា។ ស្នាដៃថ្មីនេះ មានឈ្មោះថា ***អប្សរា***។ អប្សរាត្រូវបានបំផុសគំនិតដោយរូបភាពអប្សរាពីប្រាសាទអង្គរវត្ត ដែលជាចម្លាក់លៀនចម្បងមួយដែលគេបង្កើតឡើងដោយការដាប់ក្បាច់ក្បូរសំបូរបែបនៅលើប្រាង្គប្រាសាទអង្គរវត្ត។ លើសពីនេះ ស៊េរីការងារនេះផ្តោតលើទម្រង់មនុស្ស ដោយទាញការបំផុសគំនិតពីរូបចម្លាក់បុរាណជាវិធីដែលរូបចម្លាក់សាមញ្ញឈរខ្ពស់ និងបញ្ចាក់ពីកម្លាំងខាងក្នុង ភាពស្រស់ស្អាត និងអារម្មណ៍នៃសន្តិភាព។ ជាចុងក្រោយលោកបានបង្កើតអប្សរានេះឡើងដើម្បីឧទ្ទិសដល់ទីក្រុងបុរាណអង្គរតែម្តង។

As a continuation of his previous sculptures, Manu and Devata. He recently began working on a new series called ***Apsara***. Apsara is inspired by depictions of Apsaras from the Angkor Wat Temple, an essential motif in the stone bas-reliefs of the Angkorian temples. Additionally, this series focuses on human forms, drawing inspiration from classical statues, the way in which the relatively simple figures stand tall and affirm their inner strength, beauty, and sense of peace. His Apsara collection is a dedication to the ancient city of Angkor.

Thang Sothea
APSARA, 2020
Metal, copper, hemp and wood wax
213 x 38 x 30 cm

Thang Sothea
APSARA, 2021
Metal, copper, hemp and wood wax
217 x 39 x 30 cm

Thang Sothea
APSARA, 2021
Metal, copper, hemp and wood wax
217 x 39 x 30 cm

Thang Sothea
APSARA, 2022
Metal, copper, hemp and wood wax
217 x 39 x 30 cm

Thang Sothea
APSARA, 2022
Metal, copper, hemp and wood wax
217 x 39 x 30 cm



Thang Sothea
Rise and Set, 2022
Hemp, sarong(fabrics), beeswax, wood wax
130 x 120 cm



Thang Sothea
APSARA (head), 2021
Metal, copper, hemp and wood wax
79 x 32 x 18 cm

Thang Sothea
APSARA (head), 2021
Metal, copper, hemp and wood wax
75 x 32 x 18 cm

Thang Sothea
APSARA (head), 2021
Metal, copper, hemp and wood wax
76 x 32 x 18 cm



Pen Robit
Thread/Construction 3, 2019
Oil on Canvas
155 x 120 cm

ប៉ែន រ៉ូប៊ីត / PEN ROBIT

ការងាររបស់រ៉ូប៊ីត តំណាងឲ្យភាពប្រទាក់ក្រឡានៃសង្គម និងនយោបាយរបស់ប្រទេសកម្ពុជាពីពេលអតីតកាល បច្ចុប្បន្នកាល និងពេលអនាគត។ ការងាររបស់លោកទទួលបានឥទ្ធិពលពីធាតុតំណាងវប្បធម៌ខ្មែរផ្សេងៗ ក៏ដូចជាបញ្ហាសង្គមដែលកំពុងបន្តមានសព្វថ្ងៃ។ សិល្បៈរបស់លោក ត្រូវបានគេជ្រើសរើសយកទៅដាក់តាំងនៅជាច្រើនប្រទេសដែលក្នុងនោះរួមមានសាលតាំងសិល្បៈនៅប្រទេសអូស្ត្រាលី តៃវ៉ាន់ បារាំង កម្ពុជា ថៃ និងប្រទេសមួយចំនួនទៀត។

Robit's work attempts to represent Cambodia's past, present and future socio-political fabric. He draws influences from Cambodian cultural iconography as well as ongoing societal discourse. He has been selected as an artist-in-residence for numerous festivals and art exhibition in Australia, Taiwan, France, Cambodia, Thailand and more.

ការងារដែលមានឈ្មោះថា *«សរសៃ»* របស់រ៉ូប៊ីតបានឃ្លាតចេញពីទម្រង់ដែលអាច កំណត់អត្តសញ្ញាណបាន ទៅរកភាពអរូបីនៃក្រឡាចត្រង្គ ដូចជាការសិក្សារូបដ៏ជិត នៃក្រណាត់ដូច្នោះដែរ ។ ខ្សែបន្ទាត់នៅក្នុងគំនូរទាំងនេះមិនត្រង់ឥតខ្ចោះ ហើយក៏មិន រលូនពេកនោះដែរ ប៉ុន្តែវាមានសភាពកោងពន់ពេនបន្តិច និងរត់មិនស្មើគ្នាទាំងស្រុង ទេ ដូចជាសភាពនៃកំណាត់ដែលត្បាញបែបរលុងរង្វើលដូច្នេះ ។ ដោយប្រើជក់មកគូរ មួយសរសៃម្តងៗ សិល្បករូបនេះ ដើរតួដូចជាអ្នកតម្បាញ បង្កើតខ្សែបន្ទាត់ចាក់ផ្គង គ្នាប្រកបដោយភាពអត់ធ្មត់ ។ លោកចាត់ទុកការបង្កើតសិល្បៈនេះថា ជាមធ្យោបាយ មួយដើម្បីគ្រប់គ្រង និងបន្ធូរអារម្មណ៍ខ្លួនឯង។ វាអនុញ្ញាតឱ្យលោកសញ្ជឹងគាំងចិត្ត និងផ្តោតអារម្មណ៍៖ អូសជក់ម្តងមួយខ្សែៗ ក្នុងរូបភាពដែលលោកមានការគ្រប់គ្រង ផង និងបន្ធូរផង ។ តាមរយៈដំណើរការនៃការពិនិត្យដ៏ជិតរបស់ក្រមា រ៉ូប៊ីត បានរក ឃើញនូវអត្តសញ្ញាណ និងអត្ថន័យដែលសង្គមផ្តល់ឱ្យវា ដើម្បីស្វែងរកច្រកថ្មីមួយ ឬក៏ សម្រាប់គាត់ វាតំណាងឲ្យសេរីភាពមួយ។

Thread proposes a further departure from identifiable forms toward the abstraction of grid structure like a close-up study of the fabric. The lines are not perfectly straight nor seamless, but rather slightly wavy and uneven like the nature of the loosely knitted textile. Line by line through his brush, the artist acts like a weaver patiently constructing the interlacing threads. He describes this process to calm and control himself. It allows him to slow down, meditate and focus: one thread of brush at a time in a controlled yet loose manner. Through this process of a close examination that Robit strips off social codes attached to Krama to open up a new passage, or for him a kind of freedom. It presents a moment of reflection in an artist's practice as a productive mode of artistic enquiry. Robit's return to the basics of painting and his attention on interweaving lines through paintbrush reflects his journey of unlearning and relearning as an artist. It is also a process through which an opportunity for new possibilities is given rise to, perhaps one that evades the politics of form and the grid of nationalism.



Pen Robit
Thread/Construction 1,
2019
Oil on Canvas
155 x 120 cm

Pen Robit
Thread 1, 2018
Oil on Canvas
75 x 110 cm

Pen Robit
Thread 2, 2018
Oil on Canvas
75 x 110 cm

Pen Robit
Thread/Construction 2, 2019
Oil on Canvas
155 x 120 cm

Pen Robit
Thread 3, 2018
Oil on Canvas
75 x 110 cm

Ket Monnyreak
Central Market, 2022
Acrylic on canvas
40x80cm
Unique edition

កេត មុន្នីរ័ក្ស / KET MONNYREAK

ការងាររបស់ មុន្នីរ័ក្ស ផ្តោតភាគច្រើនទៅលើខ្សែបន្ទាត់ច្បាស់ៗ រាងផ្សេងៗ និង ការប្រើពណ៌ស្រស់ឆើត រួមជាមួយនឹងការផ្គុំធាតុទាំងនោះយ៉ាងប៉ិនប្រសប់។ លោក ចូលចិត្តយកត្រាប់តាមសកម្មភាពប្រចាំថ្ងៃរបស់អ្នករស់នៅភ្នំពេញ និងស្ថាបត្យកម្ម សាមញ្ញៗ។ ការងាររបស់មុន្នីរ័ក្សបានវិវឌ្ឍពីខ្សែល្អិតៗ មកទៅជាការប្រើប្រាស់ខ្សែ និងរូបរាងសាមញ្ញៗ។ សព្វថ្ងៃលោកចូលចិត្តបង្កើតសិល្បៈជាមួយនឹងហ្វឹតអាគ្រីលិក និងការគូរតាមប្រព័ន្ធឌីជីថល។

Monnyreak's works predominantly feature crispy lines, solid shapes and vibrant colours along with dream-like composition. Phnom Penh's day-to-day activities, simple architecture and intricate composition are his main inspiration and specialty. His works have evolved from very detailed fine lines to a clean, and basic geometry. His current favorite mediums are acrylic marker and digital drawing.

មុន្នីរ័ក្ស ដាក់តាំងបង្ហាញ ***ឈុតគំនូរ Treeline Urban Resort*** ដែលបង្ហាញពីភាព ស្រស់ស្អាតរបស់សណ្ឋាគារនេះតាមរយៈស្នាដៃគូររបស់លោក។ រូបនីមួយៗមើលទៅ ហាក់បីដូចជា រូបភាពដែលដកស្រង់ពីវីដេអូនៃការដើរទស្សនកិច្ចនៅសណ្ឋាគារនេះ អញ្ចឹង។ លោកពិតជាចង់ឲ្យអ្នកទស្សនាបានទទួលបានអារម្មណ៍ហាក់បីដូចជានៅ ទីនោះផ្ទាល់តាមរយៈការមើលរូបទាំងនេះ។ ឈុតមួយទៀតដែលលោកដាក់តាំង មានឈ្មោះថា ***ឈុតគំនូរ Thriving*** គឺជាឈុតគំនូរដែលមានបន្ទាត់តែមួយ គូរដោយ

Ket Monnyreak
Treeline Set, 2020
Acrylic on cotton paper
16 x 11 cm
(Without frame)
Unique edition

ប្រើប្រាស់វិធីសាមញ្ញ ហើយបង្ហាញពីជីវិតដ៏មមាញឹករបស់ឈ្មួញអាជីវកម្មតូចៗនៅទីក្រុងភ្នំពេញ។ គោលបំណងរបស់លោកគឺចង់បង្ហាញថាដោយគ្រាន់តែប្រើវិធីគូរដ៏ងាយស្រួល និងការប្រើប្រាស់ពណ៌ យើងអាចបង្ហាញពីភាពច្នៃប្រឌិតក្នុងការគិតរបស់យើងបាន។ សិល្បៈចុងក្រោយដែលលោកដាក់តាំងមានឈ្មោះថា ផ្សារថ្មី ដែលជាស្ថាបត្យកម្មមួយដែលលោកមានការសរសើរយ៉ាងខ្លាំង។ ការលាយឡំរវាងខ្សែកោង និងខ្សែកែងធ្វើឲ្យការផលិតការងារមួយនេះសប្បាយផង ពិបាកផង។ លោកធ្លាប់បានផលិតរូបគំនូរផ្សារថ្មីពីមុនមកដែរ ប៉ុន្តែសម្រាប់គំនូរថ្មីនេះ លោកបានប្រើប្រាស់វិធីសាស្ត្រថ្មី។

Monnyreak presents ***Treeline Urban Resort Set*** which captures the beauty of Treeline through his illustrations. Each artwork is like a frame taken from a video of touring around Treeline. He really wants the viewer to feel a sense of the environment by looking at these illustrations. The other set, *Thriving Set;* thick mono-line illustrations created by simple shapes, with the subject of showing the fun, exaggerated, fast-paced lifestyle of small local business owners in Phnom Penh. The purpose is to show that you have a lot of possibilities to express your funny and lame ideas with very simple line drawing, shape and minimal color combinations. And the last piece is Central Market, an architecture that always amazes him. The combination between curve and angular line is very fun and challenging for him to recreate in different style. He has created Central Market illustrations in different style but recently he has been very into risograph printing technique, a technique that prints spot colors on different layers with a hand-made looked texture and this inspired him to mimic this technique with his favorite subject using different medium.

Ket Monnyreak
Thriving Set, 2022
Digital Canvas Printing
Dimension 35 x 35cm
3 edition + 1 AP

Ket Monnyreak
Thriving Set, 2022
Digital Canvas Printing
Dimension 35 x 35cm
3 edition + 1 AP

ប្រាក់ ដាលីន / PRAK DALIN

ប្រាក់ ដាលីន គឺជាសិល្បការនី និងស្ថាបត្យករដែលប្រើប្រាស់គ្រឿងសំណង់ និងវត្ថុធម្មជាតិដើម្បីបង្កើតជាចម្លាក់ និងការតម្លើងដែលមើលទៅហាក់បីដូចជាគ្រោងស្ថាបត្យកម្មជាក់ស្តែង ដែលចង់បង្ហាញពីស្ថានភាពការអភិវឌ្ឍនៅទីក្រុងភ្នំពេញ។ ការងាររបស់ដាលីនទទួលបានការបំផុសគំនិតពីធម្មជាតិ ដោយដាលីនប្រើគំនិត និងដំណើរការបង្កើតសិល្បៈថ្មីដើម្បីបង្ហាញវាចេញមក។ ដាលីនចូលចិត្តប្រើប្រាស់វត្ថុដែលមានស្រាប់ប៉ុន្តែបង្ហាញវាតាមរូបរាងថ្មី។

As an artist and architect, Dalin uses natural and construction materials to create sculptures and installations that appear as architectural structures, focusing on the impact of Phnom Penh's city development. Her artworks are inspired by nature and the process of conveying into visual art and installation. She experiments with different mediums and focuses on unconventional aspects of materials.

តាមរយៈទស្សនៈសិល្បៈ និងស្ថាបត្យកម្ម ដាលីនសិក្សាពីទម្រង់ រូបរាង និងពណ៌នៃវត្ថុផ្សេងៗដើម្បីយកមកបង្កើតជារូបចម្លាក់ និងការតាំងបង្ហាញ។ ការងាររបស់កញ្ញាផ្តោតទៅលើការប្រើប្រាស់វត្ថុប្រចាំថ្ងៃ ដើម្បីបង្កើតជាអត្ថន័យថ្មី ឬតួអង្គថ្មីអ្វីមួយ។ ដាលីននឹងដាក់តាំងបង្ហាញសិល្បៈដែលមានឈ្មោះថា ***Steel*** ដែលឆ្លុះបញ្ចាំងពីជីវិត និងការរស់នៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍ។ រូបរាងនៃដែកបង្កើតទៅជាភាសាមួយតាមរយៈរូបរាង និងការតម្រៀបជួររបស់វា ដោយមានការតភ្ជាប់ពីខ្សែមួយទៅខ្សែមួយ។ ការតភ្ជាប់គ្នានៃដែកហាក់បីដូចជាសម្តែងឲ្យឃើញនូវរូបភាព និងទិដ្ឋភាពនៅជុំវិញខ្លួនយើងដូចជាក្រុមមនុស្ស សហគមន៍ និងភូមិស្រុកជាដើម។

From an Art and Architecture perspective, Dalin explores and studies forms, shapes and colours with materials to create sculptures and installation. Her work focuses on creating character and meaning from conventional materials. ***Steel*** reflects construction expressing a thought about life and situation in developing countries. Those shapes are making a language with their body and direction; one line connecting to the other performing a structure that works as a composite system. Those body connections bring familiar images of our surroundings like a group of people, a community or a village.



Prak Dalin
Continuity 1, 2022
Steel round bar
35 x 70cm
Edition of 3 + 1 AP



Prak Dalin
Continuity 2, 2022
Steel round bar
35 x 70 cm
Metal
Edition of 3 + 1 AP



Prak Dalin
Formation 1, 2022
Steel round bar
35 x 70cm
Edition of 3 + 1AP



Prak Dalin
Formation 2, 2022
Steel round bar
35 x 70cm
Edition of 3 + 1AP

Hean Ransey
Razed to the Ground, Leaving just a name, 2021
Paper: Ilford Smooth Cotton Rag 310g
50 x 75 cm
Edition of 7 + 2AP

ហ៊ាន រង្សី / HEAN RANSEY

រង្សីចាប់អារម្មណ៍លើការសិក្សា និងអង្កេតលើមនុស្ស បរិស្ថាន ធម្មជាតិ និងសង្គម។ ក្រោយពីធ្វើការអស់រយៈពេល 2 ឆ្នាំជាជំនួយការថតនៅវិទ្យុផ្កាឈូក លោកក៏ចាប់ផ្តើមមានការចាប់អារម្មណ៍លើការថតរូប។ សព្វថ្ងៃលោកកំពុងធ្វើការជាអ្នកសារពត៌មានថតនៅកាសែតភ្នំពេញប៉ុស្ត៍។ លោកក៏បានសិក្សាវគ្គថតរូបបែបសហសម័យ និងឯកសារនៅគម្រោងសិល្បៈ ស-ស ហើយក៏បានបង្កើតរូបភាពសិល្បៈផ្សេងៗដើម្បីបង្ហាញពីទំនាក់ទំនងរវាងមនុស្ស និងធម្មជាតិនៅទីនោះផងដែរ។

Rangsey is interested in studying and observing humanity, the environment, nature, and society. After 2 years of experience working as a camera assistant at Lotus radio, he has taken more interest in photography. He is currently working as a photojournalist for the Phnom Penh Post. Having studied in the Contemporary and Documentary Photography class at Sa Sa Art Projects, he created his first artwork – showcasing the connection between humanity and nature.

ភ្នំមានកត់ត្រានៅក្នុង អំណាន កំណាព្យ និងចម្រៀងខ្មែរជាច្រើន។ គេពណ៌នាអំពីមាឌ កំពស់ ភាពរឹងមាំ និង សម្រស់ដ៏ស្រស់ត្រកាលរបស់វា។ ជាមួយគ្នានោះដែរ ប្រវត្តិ និងឈ្មោះភ្នំខ្លះដែលត្រូវបានដូនតាខ្មែរយើងចងក្រងជារឿងនិទានដំណាលតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់។ កាលពីក្មេង រង្សីបានអានហើយស្រមើស្រមៃហាក់ដូចជាបានឃើញទិដ្ឋភាពទាំងនោះស្រស់ៗនឹងភ្នែក ហើយវាបានជិតជាប់នៅក្នុងការចងចាំរបស់លោក។ ពេលលោកបានធ្វើដំណើរកាត់ខេត្តនានាក្នុងតំបន់ខ្ពង់រាប លោកបានជួបទិដ្ឋភាពទាំងនោះពិតមែន តែភ្នំមួយចំនួនដែលស្ថិតនៅអមតាមដងផ្លូវត្រូវបាន ចោះ ដាប់ កាប់ជីកកាយ យ៉ាងសៀមស្ងាត់ បាត់ទៅហើយ។

Razed to the Ground, Leaving just a name. Cambodian mountains are written in poems, articles and songs describing their size, height, strength and beauty. At the same time, some of the history and names of the mountains were compiled by Khmer ancestors as tales from one generation to another. As a kid, Rangsey used to read and fantasize about seeing those scenes fresh in his eyes, and they stuck in his head. But as he traveled through the highland provinces recently, he came across those views, but some of the mountains along the road were quietly pierced, excavated, and dug up.

Hean Ransey
Razed to the Ground, Leaving just a name, 2021
Paper: Ilford Smooth Cotton Rag 310g
50 x 75 cm
Edition of 7 + 2AP

Hean Ransey
Razed to the Ground, Leaving just a name, 2021
Paper: Ilford Smooth Cotton Rag 310g
50 x 75 cm
Edition of 7 + 2AP



Roeun Sokhom
Old building, 2022
Watercolour
37.50 x 55.50 cm

Roeun Sokhom
Old buildings in Phnom Penh, 2022
Watercolour
37.50 x 55.50 cm

រឿន សុខុម / ROEUN SOKHOM

សុខុម គឺជាសិល្បករឈានមុខគេមួយរូបក្នុងសហគមន៍សិល្បៈនៅខេត្តបាត់ដំបង។ ការអនុវត្តរបស់លោកផ្តោតលើការប្រើប្រាស់ពណ៌ទឹក និងគំនូរអាគ្រីលីក ក៏ដូចជាការអនុវត្តគំនូរផ្ទាល់ និងការដំឡើងជាដើម។ នៅក្នុងឆ្នាំ 2013 សុខុមបានបង្កើតស្ទូឌីយ៉ូសិល្បៈខេត្តបាត់ដំបង ដែលជាកន្លែងសិល្បៈសម្រាប់ដាក់តាំងបង្ហាញស្នាដៃរបស់សិល្បករផ្សេងទៀតនៅក្នុងទីក្រុងនោះ។ លោកបានបើកទីតាំងនេះឡើងដើម្បីបង្កើតជាកន្លែងពិភាក្សា និងជាកន្លែងតាំងពិព័រណ៍សិល្បៈផង។ សុខុម ធ្លាប់បានគេអញ្ជើញទៅសម្តែងការគូររូបផ្ទាល់សម្រាប់កម្មវិធីសៀកនៅតាមប្រទេសកម្ពុជា ជប៉ុន កូរ៉េ បារាំង និងប្រទេសមួយចំនួនទៀតនៅអឺរ៉ុប។

Sokhom is a leading figure in Battambang's dynamic art community. His practice associates the use of watercolor and acrylic painting, as well as live painting performance and installation. In 2013, Sokhom founded Battambang art studio, an art space to exhibit other artists' work in the city. He ran the space dedicated to discussion and creation, rather than an exhibition. Sokhom was on Live painting for circus shows in Cambodia, Japan, Korea, France, and Europe.

សុខុម មានដើមកំណើតនៅជាយក្រុងបាត់ដំបង។ លោករស់នៅទីនោះរហូតដល់ពេលបច្ចុប្បន្ន។ ភ្ញៀវដែលទៅលេងក្រុងបាត់ដំបងគេច្រើនតែចាប់អារម្មណ៍អគារសម័យបារាំង ហើយសុខុមក៏ចាប់ចិត្តស្រលាញ់អគារប្រភេទនេះជាខ្លាំងដែរ។ ក្នុងស៊េរីគំនូរពណ៌ទឹកថ្មីនេះ សុខុមលើកស្ទួយស្ថាបត្យកម្មពិសេសសម័យបារាំងនៅទីក្រុងបាត់ដំបង និងអគារមួយនៅទីក្រុងភ្នំពេញផងដែរ។ សុខុមបង្ហាញពីរបៀបដែលអគារទាំងនេះលាយឡំគ្នាជាមួយនឹងការអភិវឌ្ឍទីក្រុងថ្មី និងរបៀបដែលប្រជាជនប្រើប្រាស់វារាល់ថ្ងៃ ដោយខ្លះនៅរក្សារបៀបរស់នៅដដែល ខ្លះផ្លាស់ប្តូរជារបៀបថ្មី។

Roeun Sokhom was born on the edge of Battambang City, and he lived there his whole life. The colonial-era buildings in Battambang that are a favourite feature of the city for visitors have always been familiar to and fascinating for Sokhom. In this new series of watercolours, the artist celebrates the distinctive architecture of the French period in Battambang and one of buildings in Phnom Penh. He also observes, with a unique vision, the way in which these buildings are integrated into the contemporary city, and still used by the local population every day, in new and old ways.

Roeun Sokhom
Old building, 2022
Watercolour
37.50 x 55.50 cm

Roeun Sokhom
Cinema, 2022
Watercolour
37.50 x 55.50 cm

Roeun Sokhom
Old building, 2022
Watercolour
37.50 x 55.50 cm

ចាន់ ដានី / CHAN DANY

ការងាររបស់ដានី តែងផ្តោតទៅលើការធ្វើឲ្យរស់ឡើងវិញ នូវទម្រង់សិល្បៈបុរាណ តាមរយៈការបង្កើតរូបរាងថ្មីដែលសមស្របនឹងការចង់បាននៅប្រទេសកម្ពុជាបច្ចុប្បន្ន។ ដានី ប្រើប្រាស់ការគូរ ដេរ និងផ្គុំដើម្បីបង្កើតសិល្បៈរបស់លោកដោយយកទម្រង់តាមក្បាច់ និង រូបភាពនៅក្នុងទេវកថាខ្មែរ។ ការងាររបស់លោកត្រូវការភាពអត់ធ្មត់ខ្ពស់ ការធ្វើដដែលៗដូចពីជំនាន់ចាស់បុរាណ។ ការងារទាំងនេះក៏បង្ហាញពីការផ្លាស់ប្តូរនៃសិល្បៈតាមពេលវេលា និងដើរតួជាការចូលរួមអភិរក្សផងដែរ។ ។

Dany is known for reinterpreting ancient Khmer cultural forms and practices that retain aesthetic and moral ground in today's Cambodia. Whether appropriating traditional ornamental codes or mythological characters, Dany employs knowledge of codified forms and techniques ranging from painting to sewing and collaging with novel materials. His arduous and often delicate practice requires repetition and patience reminiscent of traditional master-artisan production methods, yet he embraces change and plays as forms of preservation.

កាងាររបស់ដានីគឺជាប្រភេទសិល្បៈសហសម័យដែលប្រើប្រាស់ភាពបត់បែននៃក្បាច់រចនាខ្មែរជាក្បាច់បុរាណដែលធ្វើគ្រាប់តាមធម្មជាតិ។ ការបង្កើតសិល្បៈរបស់លោកតម្រូវឲ្យមានភាពអត់ធ្មត់ និងការធ្វើដដែលៗ ដែលរំលឹកយើងពីចាស់បុរាណដែលចំណាយពេលយ៉ាងយូរក្នុងការបង្កើតអ្វីមួយ ឲ្យបានឥតខ្ចោះដូចជាការត្បាញសូត្រជាដើម។ បើមើលពីចម្ងាយ ការងាររបស់លោកហាក់បីដូចជា ក្រណាត់ប៉ាក់ដូច្នេះ ប៉ុន្តែនៅពេលដែលយើងទៅជិតវា យើងនឹងឃើញពីស្នាដៃដ៏ប៉ិនប្រសប់ និងភាពលម្អិតនៃសិល្បៈទាំងនេះ។ ជារួមការងារទាំងនេះបង្ហាញពីការវិវឌ្ឍនៃវត្ថុផ្សេងៗ និងចំណេះដឹងថ្មី។

Dany's artwork creates contemporary work that employs a flexible knowledge of kbach rachana, or Khmer decorative forms – an ancient code of organic shapes and patterns applied in different styles. His practice requires repetition and patience reminiscent of traditional master-artisan methods of production, such as silk weaving. From a distance Chan's art even resembles tapestry work, but upon closer viewing his technique is revealed. His work is about the evolution of materials and knowledge.

Chan Dany
Wildflower, 2022
Coloured pencil shavings,
glue, wood
200 x 100 cm

Chan Dany
Pumpkin flower, 2022
Coloured pencil shavings, glue, wood
37 x 30 cm

Chan Dany
Buddhapada, 2022
Coloured pencil shavings, glue, wood
40 x 40 cm

Chan Dany,
Chan Bom Leng Khloun (Chan flower transforms), 2022
Coloured pencil shavings
40 x 50 cm

ណាតាលី លី / NATALY LEE

ណាតាលី លី គឺជាអ្នករចនា និងអ្នកជំនាញថតរូប។ ការងាររបស់ណាតាលី មានតាំងពី ការរចនាម៉ូដ ការរចនាផលិតផល និងការថតរូបជាដើម ហើយតាមរយៈការងារទាំងអស់នេះ ណាតាលីចង់បញ្ចេញនូវភាពស្រស់ស្អាតនៃវត្ថុដែលយើងឃើញជារៀងរាល់ថ្ងៃ។ ណាតាលីជឿជាក់ថា ទោះបីជាពេលខ្លះវាបំបាំងខ្លួនក៏ពិតមែន ប៉ុន្តែពេលយើងផ្តួបផ្សំទស្សនវិស័យ សមាសភាព ក្តីមេត្តា និងភាពរសើបរួមគ្នា ភាពស្រស់ស្អាតនឹងលេចរូបរាងចេញមក។ តាមរយៈរូបថតរបស់អ្នកនាង ណាតាលីចង់បង្កើតឲ្យមានទំនាក់ទំនងកាន់តែជិតស្និទ្ធ និងការចេះស្រលាញ់របស់ដែលនៅជុំវិញខ្លួនយើងរាល់ថ្ងៃ។ បើយើងអាចរស់នៅបែបនេះបាន ជីវិតយើងនឹងកាន់តែមានន័យ និងកាន់តែប្រសើរឡើង។

Nataly Lee is a designer and photographer. From branding and styling to product design and photography, Nataly sees her work as a way of bringing out the beauty in everyday things. She believes that, though sometimes hidden, with the right combination of perspective, composition, compassion, and sensitivity, beauty can always be found. Through her photographs, Nataly hopes to inspire a deeper connection and appreciation for the things around us, so that we can live richer and more meaningful lives.

ណាតាលី ចូលចិត្តបង្ហាញយើងអំពីទម្រង់ដែលប្លែកៗ តាមរយៈការថតរូបពីដ្រូនបញ្ជា។ នេះជាវិធីទាក់ទាញមួយដែលអ្នកនាងប្រើ ដើម្បីបង្ហាញយើងអំពីរបៀបមើលឃើញពិភពលោកពីជ្រុងមួយផ្សេងទៀត។ រូបថតទាំងនេះត្រូវបានថតនៅកោះ Kangaroo ប្រទេសអូស្ត្រាលីក្នុងឆ្នាំ 2019 ប៉ុន្មានខែមុនពេលភ្លើងឆេះព្រៃមួយបានធ្វើឲ្យមួយភាគបីនៃកោះនេះបានឆាបឆេះ ហើយបំផ្លាញអ្វីៗគ្រប់យ៉ាង។ អ្នកនាងចង់ឲ្យរូបភាពទាំងអស់នេះបង្ហាញអំពី ពេលវេលា លំហ ភាពងាយបែកបាក់ និងភាពអត់ធន់នៃធម្មជាតិផងដែរ។

Increasingly, Nataly is drawn to abstract forms and finds shooting from drones an engaging way to show us how to see the world differently. These photographs were taken in Kangaroo Island, Australia before the wildfires ripped through a third of the island in 2019 — destroying everything in its path. The images speak of time and space and the fragility, yet also the resilience, of nature.

Nataly Lee
Boom 1, Kangaroo Island, Australia, 2019
Digital print on canvas
80x142cm
Edition 5 + 1 AP

Nataly Lee
Boom 2, Kangaroo Island, Australia, 2019
Digital print on canvas
80x142cm
Edition 5 + 1 AP

Nataly Lee
Boom 3, Kangaroo Island, Australia, 2019
Digital print on canvas
80x142cm
Edition 5 + 1 AP

Nataly Lee
Drift, Kangaroo Island, Australia, 2019
Digital print on canvas
80x142cm
Edition 5 + 1 AP

អំពីបុរីចន្ទគីរី / ABOUT BOREY CHANKIRI

បុរីចន្ទគីរី នាំមកនូវរបៀបរស់នៅថ្មីមួយដែលផ្តោតសំខាន់លើការប្រើប្រាស់ទីធ្លារបស់មនុស្ស។ ការរចនាផ្ទះនៅបុរីចន្ទគីរីកើតចេញពីការស្រាវជ្រាវរអស់រយៈពេលយ៉ាងយូរ ដើម្បីស្វែងយល់អំពីតម្រូវការពិតប្រាកដក្នុងការរស់នៅរបស់ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញ។ ដើម្បីរចនាផ្ទះ និងប្លង់មេឡើង យើងមានទស្សនវិស័យថាគុណភាពជីវិតរបស់មនុស្សអាស្រ័យនឹងរឿងពីរយ៉ាង៖ ទីមួយគឺទំនាក់ទំនងរវាងមនុស្សនឹងមនុស្ស ទីពីរគឺគុណភាពកន្លែងដែលមនុស្សរស់នៅ និងធ្វើការងារ។ តាមរយៈបុរីចន្ទគីរី ក្រុមហ៊ុនអឺបេនលែន (Urbanland) រិះរកមធ្យោបាយដើម្បីសម្រួលដល់ការរស់នៅរបស់មនុស្សដោយយកចិត្តទុកដាក់ការសាងសង់លើ សុវត្ថិភាព សន្តិសុខ មុខងារខាងក្នុងផ្ទះ សហគមន៍ ការរស់នៅ
ជិតស្និទ្ធិនឹងគ្នាជាមួយអ្នកដទៃ ការរស់នៅជិតស្និទ្ធិជាមួយធម្មជាតិបៃតង និងគិតគូរពីលំហូរខ្យល់ក្នុងផ្ទះ និងពន្លឺធម្មជាតិផងដែរ។

ការតាំងពិព័រណ៍ ***The Space in Between*** គឺជាឧទាហរណ៍នៃសកម្មភាពមួយដែលយើងធ្វើឡើងដើម្បីនាំយកម្ចាស់ផ្ទះ និងប្រជាជននៅទីក្រុងភ្នំពេញឆ្ពោះទៅកាន់ការរស់នៅដែលកាន់តែប្រសើរជាងមុន។ ម៉្យាងការដាក់តាំងពិព័រណ៍នេះក៏នឹងផ្តល់ឱកាសឲ្យអ្នកស្រលាញ់សិល្បៈអាចជួបគ្នាដើម្បីទស្សនាសិល្បៈ និងចែករំលែងចំណេះដឹងអំពីសារៈសំខាន់នៃសិល្បៈ និងស្ថាបត្យកម្មនៅក្នុងជីវិតយើង ហើយបានស្វែងយល់ពីការបង្កើតសិល្បៈផ្សេងៗក្នុងពេលតែមួយនោះផងដែរ។

Borey Chankiri brings a people-centred design philosophy to life, driven by research, to address the needs of aspirational middle class living in Phnom Penh. We embrace a design philosophy which defines that the quality of people's lives is dependent on 2 things: the quality of relationship with other people, and the quality of the spaces people live and work in. With Chankiri, Urbanland sets out to address what people care about the most – security and safety, interior functions, community and a sense of belonging, as well as incorporating the essence of nature through careful consideration of the flow of light and air inside each home.

The Space in Between exhibition is a showcase of our commitment to invite people to step forward into a better way of living by serving as a platform for art lovers to mingle and share knowledge about the importance of art and architecture in our lives as well as the making of it.

អំពីអឺបេនលែន / ABOUT URBANLAND

ក្រុមហ៊ុន អឺបេនលែន (Urbanland) ត្រូបបានបង្កើតឡើងក្នុងគោលបំណងធ្វើឲ្យជីវិតរស់នៅរបស់មនុស្សកាន់តែល្អប្រសើរជាងមុនដោយយកតម្រូវការរបស់ពួកគេមកធ្វើជាកត្តាពិចារណាចម្បងសម្រាប់រាល់ទីធ្លា កន្លែងរស់នៅ ធ្វើការ និងបទពិសោធន៍ទាំងអស់ដែលយើងបង្កើតឡើង។ ក្នុងនាមជាក្រុមហ៊ុនអចលនទ្រព្យមួយដែលប្រកាន់យកការរចនាជាធំ យើងខ្ញុំប្តេជ្ញាគាំទ្រសិល្បករ និងសហគមន៍សិល្បៈនៅប្រទេសកម្ពុជាដែលចូលចិត្ត និងស្រលាញ់ការរចនា និងស្ថាបត្យកម្ម។ ក្រុមហ៊ុនអឺបេនលែន (Urbanland) សង្ឃឹមថានឹងអាចចូលរួមចំណែកលើកស្ទួយវិស័យសិល្បៈនៅប្រទេសកម្ពុជាឲ្យបានល្អថែមមួយកម្រិតទៀត ហើយក្នុងពេលតែមួយនោះដែរក៏ផ្តល់ឱកាសឲ្យប្រជាជនខ្មែរយល់ដឹង ស្រលាញ់ និងមើលឃើញការខិតខំប្រឹងប្រែងរបស់សហគមន៍ដ៏រស់រវើកមួយនេះផងដែរ។

Urbanland is here to enrich lives by putting people at the heart of every space and experience we create. As a design-focused company, we are committed to supporting the artists and like-minded communities in Cambodia who share common inspirations in architecture and design. Urbanland hopes to be part of elevating Cambodia's arts scene to another level and at the same time, giving more access to the public to understand and appreciate the hard work of this vibrant community.

បុរី
ចន្ទគីរី
CHANKIRI PALM CREEK
BY URBANLAND

គម្រោង បុរីចន្ទគីរី អភិវឌ្ឍដោយ
URBANLAND | A MEMBER OF ISIGROUP